# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩
ខិត្តប័ណ្ណព័ត៌មាន



***ខែវិច្ឆិកា ឆ្នាំ២០២០***

ទិន្នន័យយកមកបង្ហាញនេះ គឺបានដកស្រង់ចេញពីរបាយការណ៍ចុងក្រោយនៃអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ (CIAS 2019) ដែលផលិតដោយវិទ្យាស្ថានជាតិស្ថិតិ (NIS) នៃក្រសួងផែនការ សហការណ៍ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) និងជំនួយបច្ចេកទេសដោយអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO)។ អង្គការ FAO តាមរយៈកម្មវិធី AGRISurvey បានជួយកម្ពុជាក្នុងការពង្រឹងប្រព័ន្ធនៃការអង្កេតកសិកម្មជាតិ និងដើម្បីលើកកម្ពស់ដល់ការប្រើប្រាស់ទិន្នន័យស្ថិតិកសិកម្ម។

រូបភាពទី១: ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងអនុវត្តន៍អង្កេតចន្លោះជំរឿន កសិកម្មកម្ពុជាឆ្នាំ២០១៩ពីវិទ្យាស្ថានជាតិស្ថិតិ




## ១. ទិដ្ឋភាពទូទៅនៃវិធីសាស្ត្រអង្កេត

នៅខែកក្កដា ឆ្នាំ២០១៩ ស្ថាប័នពីរនៃរាជរដ្ឋាភិបាលកម្ពុជា (NIS និង MAFF) បានសហការណ៍គ្នាធ្វើអង្កេតកសិកម្មខ្នាតធំដំបូងបង្អស់នៃវិស័យកសិកម្ម ចាប់តាំងពីការធ្វើជំរឿនកសិកម្ម កម្ពុជាឆ្នាំ២០១៣ កន្លងមក។ ការអង្កេតថ្នាក់ជាតិនេះបានប្រមូលព័ត៌មានស្តីពីការដាំដុះដំណាំ ការចិញ្ចឹមបសុសត្វ បសុបក្សី វារីវប្បកម្ម និងនេសាទ។ អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ បានប្រើវិធីសាស្ត្រស្ថិតិដោយជ្រើសរើសសំណាកគំរូ មណ្ឌលអង្កេតជាតំណាងនៅទូទាំងប្រទេសកម្ពុជា ពីក្របខ័ណ្ឌបញ្ជីនៃជំរឿនកសិកម្មឆ្នាំ២០១៣។ ក្រុមគ្រួសារនៅក្នុងមណ្ឌលអង្កេតទាំងនេះត្រូវបានចុះបញ្ជី ដើម្បីស្វែងរកគ្រួសារមានសកម្មភាពកសិកម្ម ដោយប្រើប្រាស់កម្រងសំណួរព័ត៌មានជាមូលដ្ឋាន។ គ្រួសារកាន់កាប់កសិកម្ម ត្រូវបានរកឃើញហើយបានរៀបចំធ្វើការជ្រើសរើសសំណាកគំរូតាមសកម្មភាពនីមួយៗ ដើម្បីប្រមូលព័ត៌មានសំខាន់ៗបន្ថែមទៀត។ ការកាន់កាប់កសិកម្មគតិយុទ្ធ ឬជាសហគ្រាសកសិកម្មខ្នាតធំដែលគ្រប់គ្រងដោយក្រុមហ៊ុន សាជីវកម្ម ស្ថាប័នរដ្ឋ ដីសម្បទានសេដ្ឋកិច្ច ក៏ត្រូវបានធ្វើអង្កេតផងដែរ ដោយផ្អែកលើបញ្ជីឈ្មោះដែលបានផ្តល់ដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការិយាល័យរដ្ឋាភិបាលដទៃទៀត ដែលមានទំនាក់ទំនងលើការគ្រប់គ្រងកសិដ្ឋានទាំងនោះ។ ការអង្កេតនេះបានប្រើប្រាស់ម៉ាស៊ីនថេប្លេត ក្នុងការប្រមូលទិន្នន័យដោយផ្ទាល់ជាមួយអ្នកតបសម្ភាសន៍ ដើម្បីកត់ត្រា និងគ្រប់គ្រងទិន្នន័យ។ ការចុះបញ្ជីតាមគ្រួសារត្រូវបានធ្វើឡើង ចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ការសម្ភាសដោយប្រើប្រាស់តារាងសំណួរស្នូលបានធ្វើឡើងពីថ្ងៃទី៨ ដល់ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ និងការសម្ភាសសហគ្រាសកសិកម្មខ្នាតធំ ចាប់ពីថ្ងៃទី២៤ ខែតុលា ដល់ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៩។ សរុបមន្ត្រីចុះមូលដ្ឋានជាង ៤០០នាក់ (រួមមានមន្ត្រីសម្ភាសន៍ចំនួន ៣៣៥នាក់ មន្ត្រីត្រួតពិនិត្យនៅមូលដ្ឋានចំនួន ៤៤នាក់ និងមន្ត្រីត្រួតពិនិត្យគុណភាពទិន្នន័យចំនួន ៤០នាក់) គ្រួសារប្រកបកសិកម្មសរុបចំនួន ១៥.៩៩៤គ្រួសារ បានបញ្ចប់សម្ភាសន៍ និងសហគ្រាសកសិកម្មខ្នាតធំចំនួន ១៨៦សហគ្រាបានសម្ភាសន៍ផងដែរនៅទូទាំង២៥រាជធានីខេត្តនៃប្រទេសកម្ពុជា។

រូបភាពទី២ : ទិដ្ឋភាពទូទៅនៃវិធីសាស្ត្រ




ប្រភព៖ អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩

ខិត្តប័ណ្ណព័ត៌មានស្ថិតិ នៃការអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ ២០១៩ នេះ គឺសម្រាប់តែការកាន់កាប់កសិកម្មគ្រួសារប៉ុណ្ណោះ។

រូបភាពទី៣: សិក្ខាសាលាស្តីពីការទទួលយកបច្ចេកវិទ្យាថ្មី CAPI ក្នុងការប្រមូលទិន្នន័យអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ ពីវិទ្យាស្ថានជាតិស្ថិតិ



## ២. គ្រួសារកាន់កាប់កសិកម្ម

រូបភាពទី៤: ទីតាំងតំបន់ភូមិសាស្ត្រប្រទេសកម្ពុជា




របាយការណ៍អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ ២០១៩ បានបង្ហាញថាមានគ្រួសារកសិកម្មសរុបចំនួន ១.៧២៦.០០០ គ្រួសារ (ការកាន់កាប់កសិកម្មមួយចំនួនធំត្រូវ បានរាយការណ៍ជាលក្ខណៈគ្រួសារ) នៅទូទាំងប្រទេសកម្ពុជា ហើយបានចែកជាបួនតំបន់ភូមិសាស្ត្ររួមមាន៖ តំបន់វាលទំនាបមានគ្រួសារកាន់កាប់កសិកម្មច្រើនជាងគេមានដល់ទៅ ៤២ភាគរយ បន្ទាប់មកគឺតំបន់ទន្លេសាបមាន ៣៥ភាគរយ តំបន់ភ្នំ និងខ្ពង់រាបមាន ១៥ភាគរយ និងចុងក្រោយតំបន់ឆ្នេរសមុទ្រមានតែ ៨ភាគរយ។

រូបភាពទី៥: ការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារនៅកម្ពុជា



រូបភាពទី៦: ចំនួន និងភាគរយនៃគ្រួសារកសិកម្មចែកតាមតាមតំបន់




ប្រភព៖ អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩

រូបភាពទី៧: គោលបំណងចម្បងនៃផលិតកម្មកសិកម្មរបស់គ្រួសារ




ប្រភព៖ អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩

គ្រួសារកាន់កាប់កសិកម្មនៅក្នុងប្រទេសកម្ពុជា បានរាយការណ៍ថា មានរហូតដល់ ៦១ភាគរយ ធ្វើកសិកម្មក្នុងគោលបំណងចម្បងសម្រាប់ទុកប្រើប្រាស់ក្នុងគ្រួសារ ហើយមានតែ ៣៩ភាគរយ ប៉ុណ្ណោះធ្វើកសិកម្មក្នុងគោលបំណងចម្បងសម្រាប់លក់។

រូបភាពទី៨: គោលបំណងចម្បងសម្រាប់លក់ ពីវិទ្យាស្ថានជាតិស្ថិតិ



រូបភាពទី៩: ភាគរយនៃគ្រួសារកសិកម្មបានធ្វើលើ ដីលំនៅដ្ឋាន ក្បាលដី ឬទាំងពីរ

1,726,000 គ្រួសារកសិកម្មនៅកម្ពុជា




ប្រភព៖ អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩

ក្នុងចំណោមគ្រួសារកាន់កាប់កសិកម្មសរុបចំនួន ១.៧២៦.០០០ គ្រួសារ មាន ៥៣ភាគរយ បានធ្វើសកម្មភាពកសិកម្មនៅលើដីជុំវិញលំនៅដ្ឋាន ហើយមាន ១២ភាគរយ ធ្វើសកម្មភាពកសិកម្មនៅលើក្បាលដីផ្សេងទៀត និង ៣៥ភាគរយ ធ្វើសកម្មភាពកសិកម្មនៅលើទាំងពីរ ទាំងក្បាលដី និងដីជុំវិញលំនៅដ្ឋាន។

## ៣. ផលិតកម្មដំណាំ

ការអង្កេតនេះបានបង្ហាញថា មានគ្រួសារកាន់កាប់កសិកម្មចំនួន ១.៥១៧.០០០គ្រួសារ បានធ្វើសកម្មភាពដាំដំណាំ ក្នុងចំណោមគ្រួសារកាន់កាប់កសិកម្មសរុបចំនួន ១.៧២៦.០០០គ្រួសារ។ ចំពោះមុខដំណាំគឺមានច្រើនប្រភេទ ត្រូវបានរាយការណ៍នៅអំឡុងពេលប្រមូលទិន្នន័យ ប៉ុន្តែការអង្កេតនេះគឺផ្តោតទៅលើដំណាំតែ ២០ប្រភេទដំណាំសំខាន់ៗប៉ុណ្ណោះដែលបានជ្រើសរើសដោយមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីយកមកសួរព័ត៌មានលម្អិតលើ ផ្ទៃដីដាំដុះ ការប្រមូលផល ការប្រើប្រាស់ជី ថ្នាំសំលាប់សត្វល្អិត ប្រព័ន្ធស្រោចស្រព និងផលិតកម្មដែលទទួលបាន។

រូបភាពទី១០: ដំណាំចម្បងបួនប្រភេទដែលបានដាំច្រើន ពីវិទ្យាស្ថានជាតិស្ថិតិ



រូបភាពទី១១: ដំណាំចម្បងបួនប្រភេទដែលបានដាំច្រើនជាងគេនៅតំបន់នីមួយៗ (ចំនួនគ្រួសារកសិកម្មដែលបានរាយការណ៍)

**តំបន់វាលទំនាប:**
624,000 គ្រួសារ
1. ស្រូវធម្មតា
2. ស្វាយ
3. ចេក
4. ស្រូវក្រអូប

**តំបន់បឹងទន្លេសាប:**
529,000 គ្រួសារ
1. ស្រូវធម្មតា
2. ស្វាយ
3. ចេក
4. ស្រូវក្រអូប

**1,517,000 គ្រួសារកាន់កាប់កសិកម្មបានធ្វើសកម្មភាពដាំដំណាំនៅទូទាំងប្រទេសកម្ពុជា**

**តំបន់ឆ្នេរសមុទ្រ:**
119,000 គ្រួសារ
1. ស្រូវធម្មតា
2. ដំឡូង
3. ចេក
4. ស្វាយ

**តំបន់ភ្នំ និងខ្ពង់រាប:**
246,000 គ្រួសារ
1. ស្រូវធម្មតា
2. ស្វាយចន្ទី
3. ចេក
4. ស្វាយ

ប្រភព៖ អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩

ការអង្កេតនេះបានចាត់ចំណាត់ថ្នាក់ដំណាំចម្បង ចំនួនបួនដែលគ្រួសារកសិកម្មបានដាំ នៅក្នុងតំបន់ធំទាំងបួននៃប្រទេសកម្ពុជា។ ស្រូវធម្មតាត្រូវបានរកឃើញថា ជាប្រភេទដំណាំដែលបានដាំច្រើនជាងគេបំផុតនៅទូទាំងប្រទេស ហើយបានប្រើប្រាស់ផ្ទៃដីដាំដុះដំណាំស្រូវធម្មតានេះមានសរុបចំនួន ១,៤៨ លានហិកតា និងផ្ទៃដីបានប្រមូលផលសរុបចំនួន ១,៤១ លានហិកតា។ ទិន្នផលជាមធ្យមត្រូវបានរកឃើញថាមានប្រមាណ ២.៥០៤ គីឡូក្រាមក្នុងមួយហិកតា ខណៈដែលបរិមាណផលសរុបនៅទូទាំងប្រទេសប្រមាណ ៣,៥ លានតោន។

ការអង្កេតនេះក៏បានបង្ហាញផងដែរថា ប្រទេសកម្ពុជាបានដាំដុះដំណាំហូបផ្លែជាច្រើនប្រភេទរួមមាន ស្វាយ ចេក ខ្នុរ មៀន ទឹកដោះគោ ត្របែក ទៀប ល្ហុង ព្រីង ស្រកានាគ ម្នាស់ និងទុរេន។ ដំណាំស្វាយជាដំណាំពេញនិយមជាងគេលំដាប់ទីពីរ នៅតំបន់វាលទំនាប និងតំបន់បឹងទន្លេសាបដែលកសិករបានដាំដុះ ហើយដែលបានរាយការណ៍ថា នៅទូទាំងប្រទេសផ្ទៃដីដាំដុះដំណាំស្វាយមានប្រមាណ ៩៦.៧៦៥ហិកតា និងផ្ទៃដីប្រមូលផលបានប្រមាណ ៥៥.៩៤៤ហិកតា ជាមួយបរិមាណផលសរុបប្រមាណ ៣៥៩.៧៥៨តោន។ ចំណែកនៅតំបន់ឆ្នេរសមុទ្រ និងតំបន់ភ្នំ និងខ្ពង់រាប ដំណាំដំឡូង ស្វាយចន្ទីជាដំណាំពេញនិយមបំផុតលំដាប់ទី

ពីររៀងគ្នា។ សម្រាប់ដំណាំចេកជាដំណាំពេញនិយមបំផុតលំដាប់ទីបីនៅទូទាំងបួនតំបន់នៃប្រទេសកម្ពុជា ដែលមានផ្ទៃដីដាំដុះប្រមាណ ១០.៨៧០ហិកតា ផ្ទៃដីបានប្រមូលផល ៨.៣៧៥ ហិកតា ជាមួយបរិមាណផលសរុបប្រមាណ ១៥៤.០០០តោន ។

## ៤. សកម្មភាពចិញ្ចឹមបសុសត្វ បសុបក្សី

ការចិញ្ចឹមបសុសត្វ បសុបក្សីជាសកម្មភាពកសិកម្មដ៏សំខាន់នៅក្នុងប្រទេសកម្ពុជា ជួយទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជន និងផ្តល់ចំណូលរហូតទៅដល់ ៧៥ភាគរយ នៃចំនួនសរុប ១.៧២៦.០០០គ្រួសារកាន់កាប់កសិកម្ម នៅក្នុងប្រទេស ១.៣០១.០០០គ្រួសារ។ ហើយមានប្រមាណ ១.២៧៨.០០០ គ្រួសារកសិកម្មបានរាយការណ៍ថាមានចិញ្ចឹមបសុបក្សី និងប្រមាណ ៦៥៨.០០០គ្រួសារកសិកម្មមានការចិញ្ចឹមបសត្វគោ។

ចំនួនគ្រួសារកសិកម្មដែលមានចិញ្ចឹមសត្វគោច្រើនជាងគេ គឺនៅតំបន់វាលទំនាប ២៦៩.០០០គ្រួសារ ហើយបន្ទាប់មកគឺនៅតំបន់ទន្លេសាបមាន ២១០.០០០គ្រួសារ ចំណែកនៅតំបន់ភ្នំ និងខ្ពង់រាបមានចំនួន ១១៦.០០០គ្រួសារ និងមានតិចជាងគេ នៅតំបន់ឆ្នេរសមុទ្រ ៦២.០០០គ្រួសារ។

រូបភាពទី១២: សកម្មភាពចិញ្ចឹមបសុបក្សីរបស់កសិករ ពីវិទ្យាស្ថានជាតិស្ថិតិ



រូបភាពទី១៣: ចំនួនគ្រួសារកសិកម្ម ដែលបានរាយការណ៍មានសកម្មភាពចិញ្ចឹមបសុសត្វ បសុបក្សីចែកតាមតំបន់ (គិតជាពាន់)




ប្រភព៖ អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩

នៅតំបន់វាលទំនាបដដែលនេះ ក៏មានការចិញ្ចឹមបសុបក្សីច្រើនជាងគេផងដែរគឺចំនួន ៤៩៥.០០០គ្រួសារ បន្ទាប់មកគឺតំបន់បឹងទន្លេ សាប ៤៣៨.០០០គ្រួសារ ហើយតំបន់ភ្នំមាន ១១៩.០០០ គ្រួសារ និងតំបន់ឆ្នេរសមុទ្រមានចំនួនតិចជាងគេ ១៤៦.០០០ គ្រួសារ។

នៅទូទាំងប្រទេសបានបង្ហាញថា ចំនួនគ្រួសារកសិកម្មដែលបានចិញ្ចឹមសត្វគោមាន ៧៦ភាគរយ រាយការណ៍ថាបានចិញ្ចឹមចំនួនគោ ចន្លោះពី ១ ទៅ ៤ក្បាល បើគិតជាមធ្យមភាគនៅទូទាំងប្រទេសគឺ ៣,៨ក្បាលក្នុងមួយគ្រួសារកសិកម្ម ដូចគ្នាផងដែរ គ្រួសារកសិកម្មដែលបានចិញ្ចឹមបសុបក្សី មាន ៩១ភាគរយ បានចិញ្ចឹមចំនួននៅចន្លោះពី ១ ទៅ ៤៩ ក្បាល បើគិតជាមធ្យមភាគនៅទូទាំងប្រទេសគឺ ២៨,៥ ក្បាលក្នុងមួយគ្រួសារកសិកម្ម។

## ៥. សកម្មភាពការធ្វើវារីវប្បកម្ម និងនេសាទ

ការធ្វើវារីវប្បកម្ម និងនេសាទជាសកម្មភាពបំពេញចំណូលបន្ថែមនៃគ្រួសារកសិកម្មនៅប្រទេសកម្ពុជា មានប្រមាណ ១៦ ភាគរយនៃគ្រួសារកសិកម្មបានធ្វើសកម្មភាពវារីវប្បកម្ម និងនេសាទ នេះស្មើនឹងចំនួន ២៦៨.០០០គ្រួសារ ។

រូបភាពទី១៤: ចំនួននិងភាគរយនៃគ្រួសារកសិកម្មបានរាយការណ៍ថាមានសកម្មភាព វារីវប្បកម្ម និង/ឬ នេសាទចែកតាមសកម្មភាព និងតំបន់




ប្រភព៖ អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩

តំបន់ដែលមានចំនួនគ្រួសារច្រើនបំផុត ប្រកបរបរវារីវប្បកម្ម និងនេសាទ ១១៨.០០០គ្រួសារ គឺជាតំបន់បឹងទន្លេសាប។ តំបន់ឆ្នេរ សមុទ្រ មានចំនួនគ្រួសារទាបជាងក្នុងការធ្វើវារីវប្បកម្ម និងនេសាទ ៣២.០០០គ្រួសារ ប៉ុន្តែវាមានចំណែកខ្ពស់បំផុត ២៤ ភាគរយ នៃគ្រួសារដែលចូលរួមក្នុងសកម្មភាពទាំងនេះ គួរកត់សំគាល់ថា នៅតំបន់ភ្នំ និងខ្ពង់រាបមានចំនួនគ្រួសារទាបបំផុតដែលចូលរួមក្នុងសកម្មភាពវារីវប្បកម្ម និងនេសាទចំនួន ១៧.០០០គ្រួសារ។

គ្រួសារកសិកម្មស្ទើរតែទាំងអស់ មានសកម្មភាពវារីវប្បកម្ម និងនេសាទ ភាគច្រើនពួកគេធ្វើការនេសាទតែមួយមុខ មានរហូតដល់ទៅ ៨១ភាគរយ ការនេសាទទាំងនោះគឺនេសាទតាមសមុទ្រ ឬទឹកសាប។ មានតែមួយចំណែកតូច ប្រមាណជា ៦ភាគរយ នៃគ្រួសារបានធ្វើវារីវប្បកម្មតែមួយមុខ គួរឲ្យកត់សម្គាល់ថាការធ្វើវារីវប្បកម្មភាគច្រើនគឺនៅក្នុងស្រះ ឬវាលស្រែ។ គ្រួសារកសិកម្មដែលបានមានធ្វើសកម្មភាពទាំងពីរ (វារីវប្បកម្ម និងនេសាទ) មានចំនួន ១៣ភាគរយ។

## ៦. សេដ្ឋកិច្ច

វិស័យកសិកម្មកម្ពុជា នៅតែមានសារៈសំខាន់ ដើម្បីធានាដល់ជីវភាពរស់នៅរបស់ប្រជាជន។ ប្រមាណ ៣២ភាគរយ នៃម្ចាស់កសិដ្ឋានកសិកម្មបានរាយការណ៍ថាចំណូល (៤០ ទៅ ៥៩ភាគរយ) បានមកពីកសិកម្ម។ ហើយប្រមាណ ១៧ភាគរយ មានចំណូល (៦០ ទៅ ៩៩ភាគរយ) បានមកពីកសិកម្ម។ និងប្រមាណ ៤ភាគរយ បានរាយការណ៍ទាំងអស់ (១០០ភាគរយ) ថាប្រាក់ចំណូលគ្រួសារសរុបរបស់ពួកគេ គឺទទួលបានពីសកម្មភាពកសិកម្ម។

**រូបភាពទី១៥ : ភាគរយនៃគ្រួសារកសិកម្មបានរាយការណ៍មានចំណូលពីកសិកម្ម ដោយប្រៀបធៀបទៅ នឹងឆ្នាំមុនចែកតាមតំបន់**




ប្រភព៖ អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩

ប្រាក់ចំណូលក្នុងគ្រួសារដែលបានមកពី វិស័យកសិកម្មនៅកម្ពុជា បានរាយការណ៍ថា មានចំណូលទាបជាងឆ្នាំមុនមានប្រមាណ ៣១ ភាគរយ ហើយ ៥៦ ភាគរយមានចំណូលប្រហាក់ប្រហែលទៅឆ្នាំមុន និងមានប្រមាណ ១៣ ភាគរយមានចំណូលច្រើនជាងឆ្នាំមុន។

## ប្រភព

វិទ្យាស្ថានជាតិស្ថិតិ NIS នៃក្រសួងផែនការ ធ្វើការសហការជាមួយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ របាយការណ៍ចុងក្រោយអង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ នៅខែធ្នូ ឆ្នាំ ២០២០។

## សូមទំនាក់ទំនង៖

| FAO គម្រោង AGRISurvey | |
|---|---|
| គម្រោងរួមគ្នាអង្កេតកសិកម្ម (AGRISurvey) Programme http://www.fao.org/in-action/agrisurvey/en/ | ការិយាល័យស្ថិតិ (ESS) អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ (FAO) Viale delle Terme di Caracalla 00153 Rome - Italy |
| វិទ្យាស្ថានជាតិស្ថិតិ (NIS) នៃក្រសួងផែនការ (MoP) https://www.nis.gov.kh/ | វិទ្យាស្ថានជាតិស្ថិតិ (NIS) នៃក្រសួងផែនការ (MoP) រាជរដ្ឋាភិបាលកម្ពុជា អគារ C, E និង F #386 ព្រះមុនីវង្ស Blvd សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) https://web.maff.gov.kh/ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) 255, 200 វិថីព្រះនរត្តម រាជធានីភ្នំពេញ Blvd (41) |

ឧបត្ថម្ភហិរញ្ញវត្ថុដោយ៖

ឧបត្ថម្ភបច្ចេកទេសដោយ៖